# ប្រាយម៉ារី ហែ៊ល អ៊ិកកាណៃសិសិន (ភីអេឆអូ)
## Primary Health Organisations “PHOs”

Primary Health Organisations (PHOs) គឺជាការបំរើខាងសុខភាពថ្មីមួយ។ PHOs ផ្តល់ឱកាសឱ្យប្រជាជននៅក្នុងសហគមន៏និមួយៗបញ្ចេញយោបល់ពីរបៀបបំរើសុខភាពណាដែលប្រជាជនចង់បាន ហើយធានាឱ្យប្រាកដថា ការបំរើសុខភាពផ្សេងៗគ្នា ធ្វើការជាមួយគ្នាកាន់តែមានប្រសិទ្ធិភាពឡើង។

នៅក្នុង PHO មានអ្នកចេះដឹងយ៉ាងចំណានដូចជា ដុកទ័រ, ពេទ្យគិលានុបដ្ឋាក ពេទ្យចិត្តសាស្ត្រខាងជួយសំរាលទុក្ខ អ្នកលក់ថ្នាំពេទ្យ អ្នកផ្សាយខាងសុខភាព និងអ្នកដទៃច្រើនទៀតបានចូលធ្វើការជាមួយគ្នា រួមជាមួយប្រជាជនពីសហគមន៏ផ្សេងៗទៀតផង។ គេផ្តូរយោបល់និងចំណេះទៅវិញទៅមក ដើម្បីជួយថែទាំអ្នកជម្ងឺដោយយកចិត្តទុកដាក់យ៉ាងល្អបំផុត។ ជួនកាលបើចូលរួមជាមួយ PHO គឺមានន័យថា គេយកតម្លៃព្យាបាលពីអ្នកឈឺតិច ជាងធម្មតា។

PHO និមួយៗបានចាត់ចែងឡើងដោយក្រុមប្រឹក្សាមួយដែលមានសុទ្ធតែអ្នកចេះដឹងយ៉ាងចំណានខាងសុខភាព និងប្រជាជនពីសហគមន៏ផ្សេងៗ ។អ្នកតំណាងពីសហគមន៏ទាំងនេះអាចជួយប្រាប់ទៅក្រុមបំរើសុខភាពអំពីសេចក្តីត្រូវការរបស់សហគមន៏នីមួយៗ ដើម្បីអោយក្រុម PHOផ្តល់ជំនួយតំរូវតាមសេចក្តីត្រូវការរបស់សហគមន៏ទាំងអស់នោះ។ បើអ្នកចង់ចូលរួមក្នុងការសំរេចសេចក្តីក្នុងគំរោងការណ៏អ្វីៗខាងសុខភាព សូមទៅទាក់ទងជាមួយបុគ្គលិក ខាង PHO ណាម្នាក់ ឬទាក់ទងជាមួយដុកទ័រប្រចាំគ្រួសាររបស់អ្នក ឬពេទ្យគិលានុបដ្ឋាកក៏បាន គេនឹងប្រាប់អ្នក ពីរបៀបឱ្យអ្នកចូលរួមបាន។

បើអ្នកចូលរួមផ្នែកខាងអ្នកឈឺជាមួយ PHO នោះរិតតែស្រួលទៅទៀត។ បើដុកទ័រប្រចាំគ្រួសារអ្នកបានចូលរួមជាមួយ PHO រួចទៅហើយ ពេលអ្នកឈឺទៅមើលជាមួយដុកទ័រនោះ អ្នកនឹងមានឈ្មោះចូលរួមក្នុង PHO អូតូម៉ាទិចតែម្តង ដោយមិនបាច់ធ្វើអ្វីទាំងអស់។ បើមិនច្បាស់ថាតើ ដុកទ័រប្រចាំគ្រួសារអ្នកចូលរួមជាមួយ PHO ឬអត់នោះ សូមសាកសួរដុកទ័រផ្ទាល់តែម្តងទៅ។ តំបន់ដែលក្រុមប្រឹក្សាខាងសុខភាពហៅ ខាភីធលអែនខូស ឌីសស្រ្ទិកហែ៊លប៊ដ (Capital and Coast District Health Board) ទទួលខុសត្រូវនោះ មាន PHOs ៥។ ឥឡូវគេកំពុងរៀបចំបង្កើត PHO ទី៦ទៀត សំរាប់ប្រជាជនមកពីកោះខាងប៉ាស៊ីហ្វិក។

PHOs ទាំង៥ដែលមាននៅក្នុងតំបន់ទាំងនោះគឺ :

- (Kapiti PHO) PHO នៅខាភីធី

  ទូរស័ព្ទលេខ 801-7808 ឬ 025-523-615

- Porirua Plus នៅក្នុងតំបន់ ផូរីរួ

  ទូរស័ព្ទលេខ 04 237-5993 ឬ 025 2925 143

- Tumai mo te Iwi ( ផូរីរួ នឹងតំបន់ជិតខាងជុំវិញផូរីរួ)

  ទូរស័ព្ទលេខ 237 4534

- Capital PHO  (ទីក្រុងវែលីងតុន បញ្ចូលទាំងវែលីងតុនផ្នែកខាងត្បូងនឹងផ្នែកខាងជើង រហូតដល់ចនសុនវីល)

  ទូរស័ព្ទលេខ 801-7808

- South East and City PHO (ក្នុងទីក្រុងវែលីងតុន នឹងតំបន់ផ្នែកខាងត្បូង)

  ទូរស័ព្ទលេខ 389-9906

បើចង់បានពតិមានបន្ថែមទៀតអំពី PHOs អ្នកអាច :

- បើកគេហទំព័រ C & C DHB website
  www.ccdhb.org.nz/PHO/index.htm

- បើកគេហទំព័រ Ministry of Health website
  www.moh.govt.nz

- ទូរស័ព្ទទាក់ទង C&C DHB ‘Primary Care Team’

  ឈ្មោះជូលីយ៉ា ខា (Julia Carr) ទូរស័ព្ទលេខ: (04) 803-1112

- ទាក់ទងទៅ ក្រុមសហគមន៏ខាងសុខភាពនៅខាភីធី (Kapiti Community Health Group Trust)
  ទូរស័ព្ទលេខ: (04) 298 6917

- ទាក់ទងទៅ Porirua Healthlinks

  ទូរស័ព្ទលេខ: (04) 238 4753